ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ......០១១........អ.ស.ហ.ប្រ.ក.

# ប្រកាស
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃ
# ក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ច

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបរធនបាលកិច្ច
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញអនុក្រឹត្យលេខ ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការចុះបញ្ជីបរធនបាលកិច្ច
- បានឃើញប្រកាសលេខ ០០៦ អ.ស.ហ. ប្រក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករបរធនបាលកិច្ច
- បានទទួលការឯកភាពពីក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងសម័យប្រជុំ នាថ្ងៃទី៦ ខែមករា ឆ្នាំ២០២៦

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីការបង្កើត ការរៀបចំ និងដំណើរការរបស់ "ក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ច" ដើម្បីដោះស្រាយវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច តាមបែបបទ និងនីតិវិធីជាធរមាន ប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងភាពឆាប់រហ័ស សំដៅលើកកម្ពស់កិច្ចគាំពារវិនិយោគិនក្នុងវិស័យបរធនបាលកិច្ច។

**ប្រការ២.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ច ដែលសរសេរជាអក្សរកាត់ថា "**ក.ដ.ប.**" ដើម្បីដោះស្រាយវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច ដែលអនុលោមតាមច្បាប់ស្តីពីបរធនបាលកិច្ច។

## ជំពូកទី២

## ក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ច

### ផ្នែកទី១

### សមាសភាព តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ ក.ដ.ប.

**ប្រការ៣.-**

**ក.ដ.ប.** មានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| - ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច | ១ រូប | ប្រធាន |
| - អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច | ១ រូប | អនុប្រធាន |
| - ប្រធានការិយាល័យដោះស្រាយពាក្យបណ្តឹង | ១ រូប | សមាជិក |
| - តំណាងនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច | ២ រូប | សមាជិក។ |

សមាសភាពនៃ **ក.ដ.ប.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

ការផ្លាស់ប្តូរសមាសភាពនៃ **ក.ដ.ប.** ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ តាមរយៈការស្នើសុំរបស់ **ន.ប.ធ.**។

**ប្រការ៤.-**

**ក.ដ.ប.** មានតួនាទី សិទ្ធិ និងអំណាច ដូចខាងក្រោម៖



2 USV

- រៀបចំកិច្ចប្រជុំប្រចាំឆមាស ប្រចាំឆ្នាំ ឬតាមការចាំបាច់របស់ **គ.ដ.ម.** ពាក់ព័ន្ធនឹងកិច្ចដំណើរការរបស់ **គ.ដ.ម.**
- រៀបចំ និងអនុវត្តនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ គោលការណ៍ណែនាំ វិធានការនានា និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់គាំទ្រដល់កិច្ចដំណើរការដោះស្រាយវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច
- ពិនិត្យ និងដោះស្រាយវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ចដែលផ្សះផ្សាមិនសះជា
- ស្នើសុំជ្រើសរើស និងចាត់តាំងអ្នកដោះស្រាយវិវាទបរធនបាលកិច្ច
- ស្នើសុំផ្លាស់ប្តូរអ្នកដោះស្រាយវិវាទ តាមការចាំបាច់។

## ផ្នែកទី២
## លេខាធិការដ្ឋាន

**ប្រការ៥.-**

**គ.ដ.ម.** មានការិយាល័យដោះស្រាយពាក្យបណ្តឹង នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ចជាលេខាធិការដ្ឋាន និងសេនាធិការផ្នែករដ្ឋបាលនិងបច្ចេកទេស ដើម្បីធានានិរន្តរភាព និងភាពប្រទាក់ក្រឡាគ្នានឹងបែបបទនិងនីតិវិធីផ្សះផ្សា និងដោះស្រាយវិវាទ ព្រមទាំងធានាប្រក្រតីភាពនៃកិច្ចដំណើរការរបស់ខ្លួន។

**ប្រការ៦.-**

លេខាធិការដ្ឋានមានតួនាទី និងភារកិច្ច ជាអាទិ៍៖

- សម្របសម្រួលទទួលពាក្យបណ្តឹង និងសំណុំរឿងវិវាទ ដែលស្នើសុំឱ្យមានការដោះស្រាយវិវាទដោយ **គ.ដ.ម.**
- សម្របសម្រួលរៀបចំកិច្ចប្រជុំរបស់ **គ.ដ.ម.** និងកិច្ចប្រជុំដោះស្រាយវិវាទ
- រៀបចំកំណត់ហេតុ និងរបាយការណ៍កិច្ចប្រជុំរបស់ **គ.ដ.ម.**
- ចូលរួមសហប្រតិបត្តិការដោះស្រាយវិវាទ ចំពោះរាល់វិវាទពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច
- ប្រមូល និងចងក្រងរាល់សំណុំរឿងវិវាទ បណ្តឹង កំណត់ហេតុសម្រុះសម្រួល និងសេចក្តីសម្រេចរបស់ **គ.ដ.ម.** ពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តការងារដោះស្រាយវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច
- រៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ នៃការដោះស្រាយវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច
- គាំទ្រការងារទូទៅរបស់ **គ.ដ.ម.**
- អនុវត្តភារកិច្ចផ្សេងទៀតតាមការកំណត់របស់ **គ.ដ.ម.**។

លេខាធិការដ្ឋានអាចស្នើសុំប្រធាន **គ.ដ.ម.** ចាត់តាំងអ្នកដោះស្រាយវិវាទបរធនបាលកិច្ច ដើម្បីដោះស្រាយវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច។

## ផ្នែកទី៣
## កិច្ចដំណើរការរបស់ គ.ដ.ម.

**ប្រការ៧.-**

កិច្ចប្រជុំរបស់ **គ.ដ.ម.** អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការចូលរួមពីសមាជិកនៃ **គ.ដ.ម.** សំឡេងភាគច្រើន។ ក្នុងករណីចាំបាច់ ប្រធាន **គ.ដ.ម.** អាចប្រគល់ជូនអនុប្រធាន ដើម្បីដឹកនាំកិច្ចប្រជុំជំនួសបាន។

សេចក្តីសម្រេចរបស់ **ក.ដ.ម.** ត្រូវអនុម័តតាមសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណី សំឡេងស្មើគ្នា សំឡេងប្រធាន **ក.ដ.ម.** មានឧត្តមានុភាព។

**ក.ដ.ម.** អាចស្នើសុំអគ្គនាយកនៃ **ន.ម.ធ.** ក្នុងការអញ្ជើញតំណាងក្រសួង-ស្ថាប័ន ឬអាជ្ញាធរពាក់ព័ន្ធ អ្នកឯកទេស ឬមន្ត្រីជំនាញចូលរួមប្រជុំ ឬផ្តល់យោបល់ តាមការចាំបាច់។

**ប្រការ៨.-**

បន្ទាប់ពីបានពិនិត្យលើសំណុំរឿងវិវាទដែលទទួលបានពីអ្នកផ្សះផ្សា ឬភាគីវិវាទ **ក.ដ.ម.** អាចបដិសេធ ឬទទួលយកសំណុំរឿងវិវាទនោះមកដោះស្រាយនៅ **ក.ដ.ម.** តាមបែបបទ និងនីតិវិធីជាធរមាន។

**ប្រការ៩.-**

**ក.ដ.ម.** ត្រូវរាយការណ៍ជាប្រចាំអំពីវឌ្ឍនភាពនៃការដោះស្រាយវិវាទជូន **ន.ម.ធ.**។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**ប្រការ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១.-**

អគ្គលេខាធិការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អគ្គនាយកនៃនិយ័តករ ប្រធានអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៧៨ ១០កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មករា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពនិងសមាសភាពក្រុមប្រឹក្សានៃ អ.ស.ហ. "ដើម្បីជូនជ្រាប"
- ដូចប្រការ១១ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ